**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**
**លេខ** ០៦/២០០៥.កបធ

**សូមក្រាបថ្វាយបង្គំទូល**
**ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី**
**ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា**

សូមទ្រង់ព្រះមេត្តាជ្រាប ។

**__កម្មវត្ថុ__** : បណ្ដឹងរបស់លោក **ខែម វាសនា** ។
**__យោង__** : ព្រះរាជសារ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ២០០៥

ទូលព្រះបង្គំយើងខ្ញុំ សូមក្រាបបង្គំទូលថ្វាយព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងសូមទ្រង់ព្រះមេត្តាជ្រាប នៅថ្ងៃទី ១៤ ខែ មីនា ឆ្នាំ ២០០៥ ទូលព្រះបង្គំយើងខ្ញុំបានទទួលព្រះរាជសារ ចុះថ្ងៃទី ០៩ ខែ មីនា ឆ្នាំ២០០៥ ដោយភ្ជាប់មកនូវពាក្យបណ្ដឹងរបស់លោក **ខែម វាសនា** ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥ និង កាលពីថ្ងៃទី ១១ ខែ មីនា ឆ្នាំ ២០០៥ ក្រុមប្រឹក្សាធម្មនុញ្ញក៏បានទទួលពាក្យបណ្ដឹងលោក **ខែម វាសនា** លេខ ០០២៤ គសចជន ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៥។ ក្នុងសម័យប្រជុំរបស់ខ្លួននាថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥ ក្រុមប្រឹក្សាធម្មនុញ្ញយល់ឃើញថា ពាក្យបណ្ដឹងដែលថ្វាយទៅព្រះករុណា និងពាក្យបណ្ដឹងមកក្រុមប្រឹក្សាធម្មនុញ្ញមានខ្លឹមសារដូចគ្នា ហើយខ្លឹមសារនោះលាយឡំទៅដោយទិដ្ឋភាពផ្នែកច្បាប់ និង ទិដ្ឋភាពនយោបាយ ។ ចំពោះទិដ្ឋភាពនយោបាយ ក្រុម-ប្រឹក្សាធម្មនុញ្ញមិនយកមកពិនិត្យទេ ពីព្រោះមិនស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន។

អំពីទិដ្ឋភាពផ្នែកច្បាប់វិញ ពិនិត្យតាមបណ្ដឹង ឃើញថាមានពាក់ព័ន្ធនឹងការបង្កើតគណបក្សនយោបាយដែលមានចែងក្នុងមាត្រា ៩ មាត្រា ១១ ជំពូក ទី ២ នៃច្បាប់ស្ដីពីគណបក្សនយោបាយ និងការចុះបញ្ជីគណបក្សនយោបាយដែលមានចែងក្នុង មាត្រា ១៩ មាត្រា ២០ មាត្រា ២១ មាត្រា ២២ មាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ និងមាត្រា ២៦ ជំពូកទី ៥ ស្ដីពីការចុះបញ្ជី គណបក្សនយោបាយនៃច្បាប់នេះ។ ដូច្នេះភាគីដែលពាក់ព័ន្ធត្រូវអនុវត្តឱ្យស្របតាមមាត្រាទាំង ១០ ខាងលើនេះ។

តាមខ្លឹមសារនៃពាក្យបណ្ដឹង បង្ហាញឱ្យឃើញថា វិវាទកម្មកើតមាននៅពេលដែលលោក**ខែម វាសនា** ទទួលបានលិខិតលេខ ៤៧៨ សជណ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៤ របស់ក្រសួងមហាផ្ទៃ។

ឆ្លងតាមការពិនិត្យលើសំណុំឯកសារ និងតាមការសាកសួរភាគីទាំពីរ បង្ហាញឱ្យឃើញថា :

- លោក **ខែម វាសនា** បានធ្វើពាក្យស្នើសុំបើកគណបក្សសហព័ន្ធចលនាជាតិនិយម និង ចុះបញ្ជីគណបក្សនយោបាយមកក្រសួងមហាផ្ទៃ តាមរយៈលិខិតលេខ ០០៥ គសចជន ចុះថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៤ ដោយមានភ្ជាប់ នូវប្រវត្តិរូបរបស់លោកផង ។

- ក្រសួងមហាផ្ទៃ បានឆ្លើយតបតាមលិខិតលេខ ០៨៣ សជណ ចុះថ្ងៃទី ២១ ខែ ឆ្នាំ ដដែល ថាក្រសួងមហាផ្ទៃ បានទទួលសេចក្ដីជូនដំណឹង ស្ដីពីការបង្កើតគណបក្សសហព័ន្ធចលនាជាតិនិយមហើយ ប៉ុន្តែមិនអនុញ្ញាតឱ្យ

បង្កើតទេ ដោយមូលហេតុមិនបានបំពេញបែបបទត្រឹមត្រូវតាមមាត្រា ៩ ជំពូកទី ២នៃច្បាប់ស្តីពីគណបក្សនយោបាយ ដែលតម្រូវឱ្យមានប្រជាពលរដ្ឋយ៉ាងតិច ៨០ នាក់ ហើយដែលមានទីលំនៅជាអនិន្ត្រៃយ៍នៅ ក្នុងព្រះរាជាណាចក្រកម្ពុជា និងសញ្ញាសម្គាល់របស់គណបក្ស ដែលមិនស្របតាមចំណុចទី ៣ នៃមាត្រា ១១ ជំពូកទី ២ នៃច្បាប់នេះ(សញ្ញាសម្គាល់របស់ គណបក្សនយោបាយមិនត្រូវចម្លង ឬយកតាមសញ្ញាជាតិ រូបភាពតំណាងឱ្យ សាសនា ប្រាសាទអង្គរ ឬព្រះឆាយាល័ក្ខណ៍ ឬរូបសំណាករបស់ព្រះមហាក្សត្រខ្មែរគ្រប់ព្រះអង្គ) ។

- លោក **ខែម វាសនា** បានធ្វើពាក្យស្នើសុំបើកគណបក្សជាថ្មី តាមរយៈលិខិតលេខ ០០១៣ គសចជន ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០០៤ ដោយមានភ្ជាប់មកជាមួយនូវប្រវត្តិរូបសមាជិកចំនួន ៧ នាក់។

- ក្រសួងមហាផ្ទៃ បានឆ្លើយតបតាមលិខិតលេខ ៣២៨ សជណ ចុះថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ថា លោក **ខែម វាសនា** នៅតែមិនទាន់បានបំពេញឯកសារគ្រប់គ្រាន់ និងត្រឹមត្រូវតាមការជូនដំណឹងពីលើកមុន ។

- លោក **ខែម វាសនា** បានធ្វើពាក្យសុំបើកគណបក្សនេះតាមរយៈលិខិតលេខ ០០១៤ គសចជន ចុះថ្ងៃទី ២២ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ដោយភ្ជាប់មកជាមួយនូវសញ្ញាគណបក្ស (ដែលបានកែតម្រូវ) និងបញ្ជីរាយនាមស្ថាបនិក ទាំង៨០ នាក់ ដែលមាន ថ្ងៃ ខែ ឆ្នាំ កំណើត និងអាស័យដ្ឋាន ដែលស្នាក់នៅទីស្នាក់ការបណ្តោះអាសន្ន គណបក្សនេះទាំងអស់ ។

- ក្រសួងមហាផ្ទៃបានឆ្លើយតបតាមលិខិតលេខ ៤៧៨ សជណ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០០៤ ថាក្រសួងបានពិនិត្យលើសំណុំលិខិតស្តីពីការសុំបង្កើតគណបក្សនយោបាយនេះ ឃើញនៅមានភាពមិនប្រក្រតីលើស្នាមមេដៃនិងអាស័យដ្ឋានរបស់សមាជិកស្ថាបនិកទាំង ៨០នាក់ ដូច្នេះក្រសួងមហាផ្ទៃមិនទាន់អនុញ្ញាតឱ្យបង្កើតគណបក្សនេះទេ ដោយត្រូវធ្វើការស្រាវជ្រាវសិន ។ ក្រោយពីស្រាវជ្រាវរួច ទើបជូនដំណឹងស្តីពីការយល់ព្រម ឬមិនយល់ព្រមឱ្យបង្កើត។

ផ្អែកទៅលើខ្លឹមសារវាក្យខ័ណ្ឌទី ១ មាត្រា ៩ ជំពូកទី ២ ក្នុងការបង្កើតគណបក្សនយោបាយ គឺ ប្រជាពលរដ្ឋខ្មែរចំនួនយ៉ាងតិច ៨០នាក់ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ ហើយដែលមានទីលំនៅអចិន្ត្រៃយ៍នៅក្នុង ព្រះរាជាណាចក្រកម្ពុជា មានសិទ្ធិផ្តើមបង្កើតគណបក្សនយោបាយមួយ ដោយគ្រាន់តែជូនដំណឹងជាលាយលក្ខអក្សរទៅក្រសួងមហាផ្ទៃប៉ុណ្ណោះ ដោយមិនតម្រូវឱ្យធ្វើពាក្យសុំឱ្យបង្កើតនោះទេ។ ចំណែកក្រសួងមហាផ្ទៃ បទបញ្ញត្តិក្នុងវាក្យខ័ណ្ឌខាងលើនេះតម្រូវឱ្យឆ្លើយតបជាលាយលក្ខអក្សរ ថាបានទទួលសេចក្តីជូនដំណឹងនេះក្នុងរយៈពេលយ៉ាងយូរ ១៥ ថ្ងៃ ដោយមិនតម្រូវឱ្យមានការអនុញ្ញាតឱ្យបង្កើត ឬ មិនឱ្យបង្កើតគណបក្សនយោបាយនោះទេ។

- ចំពោះចំណុចដែលទាក់ទងនឹងអាស័យដ្ឋាន តាមការលើកឡើងរបស់លោក **ខែម វាសនា** ថា ក្រសួងមហាផ្ទៃទាមទារឱ្យធ្វើប័ណ្ណគ្រួសារតែមួយនៃសមាជិកស្ថាបនិកទាំងអស់ ប៉ុន្តែលោក **ខែម វាសនា** យល់ថា មិនចាំបាច់តម្រូវឱ្យមានប័ណ្ណគ្រួសារដូចក្រសួងមហាផ្ទៃទាមទារនោះឡើយនិងចាត់ទុកករណីនេះជាការរំលោភច្បាប់។

បញ្ហាខ្វែងគ្នាត្រង់ចំណុចធ្វើប័ណ្ណគ្រួសារនេះ បើដោះស្រាយរវាងភាគីទាំងពីរមិនបាន រឿងក្តី នេះចាត់ជាក្តីរដ្ឋបាល ដែលត្រូវតែដោះស្រាយតាមរយៈតុលាការ ស្របតាមវាក្យខ័ណ្ឌទី ៣ មាត្រា ១២៨ ថ្មី នៃរដ្ឋធម្មនុញ្ញដែលចែងថា " *អំណាចតុលាការគ្របដណ្តប់លើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង* " ។

- ចំពោះចំណុចដែលទាក់ទងនឹងស្នាមមេដៃ តាមការលើកឡើងរបស់លោក **ខែម វាសនា** ក៏តម្រូវឱ្យមានការស្រាវជ្រាវលើភាពមិនប្រក្រតីពីក្រសួងមហាផ្ទៃ ប៉ុន្តែតាមលោក **ខែម វាសនា** ថា ជាស្នាមមេដៃពិតរបស់ស្ថាបនិកគណបក្សសហព័ន្ធចលនាជាតិនិយម ហើយព្រមទាំងលើកឡើងថាក្រសួងមហាផ្ទៃបច្ចុប្បន្នមិនទាន់មានបច្ចេកទេសគ្រប់គ្រាន់ក្នុងការត្រួតពិនិត្យទៀតផង។

តាមការអះអាងរបស់លោក **ឡាយ ទេវហារិទ្ធ** តំណាងក្រសួងមហាផ្ទៃបានលើកឡើងថា " *តាមលិខិតលេខ ០១៥ សជណ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ២០០៥ របស់ឯកឧត្តម អគ្គស្នងការនគរបាលជាតិ បញ្ជាក់ថា ឆ្លងតាមការ ពិនិត្យរបស់នាយកដ្ឋានបច្ចេកទេសវិទ្យាសាស្ត្រទៅលើស្នាមក្រយៅដៃចំនួន ៨០នាក់ ដែលបានផ្ដិតលើបញ្ជីរាយនាមស្ថាបនិកនៃគណបក្សសហព័ន្ធចលនាជាតិនិយម ជាលទ្ធផលបានឱ្យដឹងថា ជាស្នាមក្រយៅដៃដែលផ្ដិតឡើងដោយមនុស្សតែម្នាក់ ។*"

បញ្ហាខ្វែងគ្នាត្រង់ចំណុចស្នាមមេដៃនេះក៏ត្រូវដោះស្រាយតាមរយៈតុលាការដែរ ។

យោងតាមពាក្យបណ្ដឹង តាមការពិនិត្យស្រាវជ្រាវលើសំណុំឯកសារ និងការសាកសួរភាគីទាំងពីរឃើញថា ភាគីទាំងពីរកំពុងតែអនុវត្តតាមនីតិវិធីនានាក្នុងការបង្កើតគណបក្សនយោបាយដែលតម្រូវដោយច្បាប់នេះ ។

ដូច្នេះក្រសួងមហាផ្ទៃមិនទាន់ឈានទៅដល់ដំណាក់កាលអនុវត្តតាមបទបញ្ញត្តិនៃមាត្រា ២១ មាត្រា ២២ មាត្រា ២៣ និង មាត្រា ២៤ នៃច្បាប់ស្ដីពីគណបក្សនយោបាយនេះ ដែលនាំទៅដល់ឱ្យមានការយល់ព្រម ឬបដិសេធឱ្យចុះបញ្ជីគណបក្សនយោបាយនៅឡើយទេ ។

ការប្ដឹងមកក្រុមប្រឹក្សាធម្មនុញ្ញ ដោយពុំទាន់មានការសម្រេចមិនយល់ព្រមឱ្យចុះបញ្ជីគណបក្សនយោបាយពីក្រសួងមហាផ្ទៃមិនអាចឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យស្របតាមវាក្យខ័ណ្ឌទី១ មាត្រា ២៥ នៃច្បាប់ស្ដីពីគណបក្សនយោបាយដែលចែងថា " *គណបក្សនយោបាយដែលក្រសួងមហាផ្ទៃបានចេញលិខិតមិនយល់ព្រមឱ្យចុះបញ្ជីគណបក្សនយោបាយដូចមានចែងក្នុងមាត្រា ២៤ នៃច្បាប់នេះ គណបក្សនយោបាយនោះមានសិទ្ធិប្ដឹងទៅក្រុមប្រឹក្សាធម្មនុញ្ញ*" និងចំណុចទី៤មាត្រា ២៦ នៃច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញបានចែងថា " *លើបណ្ដឹងតវ៉ារបស់គណបក្សនយោបាយពីការមិនព្រមចុះបញ្ជីគណបក្សនយោបាយ ។ បណ្ដឹងនេះត្រូវធ្វើឡើងក្នុងរយៈពេល ៥ ថ្ងៃយ៉ាងយូរ ក្រោយពីបានទទួលលិខិតជូនដំណឹងរបស់ក្រសួងមហាផ្ទៃ ។...* " នោះបានទេ ។

សេចក្ដីដូចបានក្រាបបង្គំទូលថ្វាយខាងលើនេះ ទូលព្រះបង្គំយើងខ្ញុំ បានសម្រេចធ្វើលិខិតលេខ ៥/២០០៥ កបធ.សជណ ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥ ជូនលោក ខែម វាសនា ដែលទូលបង្គំយើងខ្ញុំសូមព្រះរាជានុញ្ញាតដាក់ថ្វាយភ្ជាប់មកជាមួយនេះ ។

សេចក្ដីគួរពុំគួរ សូមទ្រង់ព្រះមេត្តាប្រោស ។

ក្រាបបង្គំទូលថ្វាយនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ២០០៥

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**